ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០០៨ សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨

# ប្រកាស
## ស្តីពី
## ការបង្វិលសងវិញនូវពន្ធ និង អាករគយ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស / រកម / ០៧០៧ / ០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

អនុញ្ញាតឲ្យទីចាត់ការគយ និងរដ្ឋាករធ្វើការបង្វិលសងវិញ ទាំងស្រុង ឬ ភាគខ្លះនូវពន្ធ និងអាករនាំចូល ព្រមទាំងទឹកប្រាក់ផ្សេងៗទៀតដែលបានបង់រួច ចំពោះ ៖


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

១. ការបង់លើសដោយប្រការណាមួយ រាប់បញ្ចូលទាំងករណីដែលបណ្តាលមកពីការភ័ន្តច្រឡំរដ្ឋបាលផង ។

២. ទំនិញនាំចូល ដែលនៅមុនពេលអនុញ្ញាតឲ្យយកចេញពីគយត្រូវពិនិត្យឃើញថា តិចជាង បែកបាក់ ខូចខាត គុណភាពទាប និងទំនិញនាំចេញទៅវិញ ឬបំផ្លាញចោលក្រោមការគ្រប់គ្រងឃ្លាំមើលរបស់គយ ទោះបីនៅក្រោយពេលអនុញ្ញាតឲ្យយកចេញពីគយរួចហើយក៏ដោយ ឬក្នុងករណីមានការផ្លាស់ប្តូររបបគយក្តី ។

៣. ការបង់លើស ដែលបានរកឃើញ តាមរយៈសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកដោះស្រាយការតវ៉ា ដូចមានចែងក្នុងបញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីគយ ឬដោយតុលាការមានសមត្ថកិច្ច ។ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកដោះស្រាយការតវ៉ា រួមមាន នាយកទីចាត់ការគយ និងរដ្ឋាករ ជាអាជ្ញាធរថ្នាក់ទី មួយ និងគណៈកម្មការតារាងពន្ធគយ ជាអាជ្ញាធរថ្នាក់ទី ពីរ ។

**ប្រការ ២ .-**

ការបង្វិលសងវិញអាចធ្វើឡើងចំពោះ ពន្ធ និងអាករនានា ដែលបានបង់នាពេលនាំចូលលើសម្ភារៈវត្ថុធាតុដើម ដែលបានប្រើប្រាស់ដោយផ្ទាល់ក្នុងការផលិត ឬបង្កើតទំនិញនៅព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបាននាំចេញ ។

ការបង្វិលសងវិញដូចមានចែងក្នុងប្រការនេះ ត្រូវមានការអនុញ្ញាតជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ទីចាត់ការគយ និងរដ្ឋាករ លើករណីដោយឡែកនីមួយៗ ។

**ប្រការ ៣ .-**

ការបង្វិលសងវិញដូចមានចែងក្នុងប្រការខាងលើ ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម ៖

១. សំណើសុំបង្វិលសងវិញត្រូវធ្វើឡើងជាលាយល័ក្ខអក្សរ ហើយដាក់ជូនទីចាត់ការគយ និងរដ្ឋាករ ដោយអមជាមួយនូវឯកសារភ្ជាប់ពាក់ព័ន្ធនានា រួមមានប្រតិវេទន៍គយ បង្កាន់ដៃពន្ធ អញ្ញត្តិប័ណ្ណ របាយការណ៍ត្រួតពិនិត្យទំនិញ វិញ្ញាបនប័ត្របំផ្លាញចោលដែលមានចុះហត្ថលេខាមន្ត្រីគយ ប្រតិវេទន៍នាំចេញ ដែលមានការបញ្ជាក់ពីគយ និងឯកសារឆ្លងកាត់ជាដើម ។

២. សំណើសុំបង្វិលសងវិញដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវធ្វើឡើងក្នុងរង្វង់ មួយ(១) ឆ្នាំ គិតចាប់ពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយនាំចូល ឬក្នុងរង្វង់មួយ (១) ឆ្នាំគិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកដោះស្រាយការតវ៉ា ឬតុលាការមានសមត្ថកិច្ច ។

៣. សំណើសុំបង្វិលសងវិញដូចមានចែងក្នុងប្រការ ២ ខាងលើ ត្រូវធ្វើឡើងតែក្នុងលក្ខខណ្ឌ ដែលទំនិញផលិតចេញពីសម្ភារៈវត្ថុធាតុដើមនាំចូល ត្រូវបាននាំចេញក្នុងរង្វង់ មួយ (១) ឆ្នាំគិតចាប់ពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយនាំចូលនៃទំនិញជាសម្ភារៈវត្ថុធាតុដើមដែលបាននាំចូលដោយបង់ពន្ធ និងអាករ ហើយប្រើប្រាស់សម្រាប់ផលិតទំនិញនាំចេញនោះ ។

**ប្រការ ៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ .-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានា ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ៥
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ